# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# ស្តីពីការពិគ្រោះយោបល់លើការកំណត់ថ្លៃសេវាបញ្ជូន និងថ្លៃលក់អគ្គិសនីឱ្យក្រុមហ៊ុន TPLC Holdings Co., Ltd ដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងអតិថិជនធុនធំ នៅតាមគន្លងខ្សែបញ្ជូនរង២២គីឡូវ៉ុលរបស់ក្រុមហ៊ុន

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជំរាបជូនអាជ្ញាធរមូលដ្ឋាន អ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនី និងសាធារណជន ដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងតំបន់ធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនី នៅតាមគន្លងខ្សែបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន TPLC Holdings Co., Ltd តាមបណ្តោយផ្លូវជាតិលេខ៦អា ចាប់ពីភូមិខ្នរ សង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ ទៅដល់តំបន់ថ្នល់កែង ឃុំសំបួរ ស្រុកបាធាយ ខេត្តកំពង់ចាម, តាមបណ្តោយផ្លូវលេខ៦១ ចាប់ពីថ្នល់កែង ទៅដល់តំបន់ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល និងចាប់ពីតំបន់ឃុំព្រែកតាមាក់ ទៅដល់ឃុំព្រះប្រសប់ និងតំបន់ឃុំពុកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ឱ្យបានជ្រាបថា កន្លងមកអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាប័ណ្ណបញ្ជូនរងឱ្យក្រុមហ៊ុន ដើម្បីធ្វើការបញ្ជូនអគ្គិសនីពីអគ្គិសនីកម្ពុជាផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងអតិថិជនប្រើតង់ស្យុងមធ្យម ដែលស្ថិតនៅតាមគន្លងខ្សែបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន។ យោងតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងកំណត់ថ្លៃសេវាបញ្ជូនអគ្គិសនី ដែលក្រុមហ៊ុនត្រូវយកបន្ថែមពីអ្នកទិញអគ្គិសនី ដូចក្នុងតារាងខាងក្រោម ÷

| **ប្រភេទអតិថិជន<br>(តង់ស្យុងមធ្យម)** | **ថ្លៃសេវាបញ្ជូនអគ្គិសនី<br>ក្នុង១គីឡូវ៉ាត់ម៉ោង** | **អត្រាថ្លៃអគ្គិសនីក្នុង១គីឡូវ៉ាត់ម៉ោង<br>ត្រូវស្មើនឹង** |
|---|---|---|
| សម្រាប់អតិថិជនអ្នកកាន់<br>អាជ្ញាប័ណ្ណចែកចាយ | ១២០រៀល | អត្រាថ្លៃអគ្គិសនីទិញពីអគ្គិសនីកម្ពុជា<br>បូកថ្លៃសេវាបញ្ជូន |
| សម្រាប់អតិថិជនប្រើតង់ស្យុងមធ្យម | ២០០រៀល | អត្រាថ្លៃអគ្គិសនីទិញពីអគ្គិសនីកម្ពុជា<br>បូកថ្លៃសេវាបញ្ជូន |

តាមខ្លឹមសារនៃកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន TPLC Holdings Co., Ltd ថ្លៃទិញអគ្គិសនីពីអគ្គិសនីកម្ពុជាមានអត្រាថ្លៃ៦៣០រៀលក្នុង១គីឡូវ៉ាត់ម៉ោង។ ដូច្នេះ អត្រាថ្លៃអគ្គិសនីដែលផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ **ស្មើនឹង៦៣០រៀល បូកនឹងថ្លៃសេវាបញ្ជូន១២០រៀលក្នុង១គីឡូវ៉ាត់ម៉ោង** និងអត្រាថ្លៃអគ្គិសនីផ្តល់ឱ្យអតិថិជនប្រើតង់ស្យុងមធ្យម **ស្មើនឹង៦៣០រៀល បូកនឹងថ្លៃសេវាបញ្ជូន២០០រៀលក្នុង១គីឡូវ៉ាត់ម៉ោង**។ ថ្លៃទិញប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជា នឹងត្រូវកែសម្រួលថយចុះជាងមុនបន្តិចនៅពេលបន្តិចទៀត ដូច្នេះនៅពេលកែសម្រួលរួច អត្រាថ្លៃទិញប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជា ដែលយកមកគិតថ្លៃអគ្គិសនីនឹងទាបជាង៦៣០រៀល។ ហើយពេលនោះ ថ្លៃអគ្គិសនីដែលត្រូវផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងអតិថិជនប្រើតង់ស្យុងមធ្យម និងថយចុះទៅតាមការចុះថ្លៃនេះ។

ដើម្បីឱ្យមានតម្លាភាព អាជ្ញាធរអគ្គិសនីកម្ពុជាស្នើសុំឱ្យក្រសួង–ស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងសាធារណជនទាំងអស់មេត្តាពិនិត្យ និងផ្តល់មតិយោបល់លើគម្រោងកំណត់ថ្លៃសេវាបញ្ជូន ឱ្យក្រុមហ៊ុន TPLC Holdings Co., Ltd សម្រាប់ផ្គត់ផ្គង់ប្រភពអគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងអតិថិជនប្រើតង់ស្យុងមធ្យម ដែលស្ថិតនៅតាមគន្លងខ្សែបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១០**។ ក្រោយថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១០ គម្រោងកំណត់ថ្លៃសេវាបញ្ជូន ឱ្យក្រុមហ៊ុន TPLC Holdings Co., Ltd សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងអតិថិជនប្រើតង់ស្យុងមធ្យម ដែលស្ថិតនៅតាមគន្លងខ្សែបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន នឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងអាចធ្វើការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីនេះ ទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឱ្យ **ការផ្តល់យោបល់មកឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា មានមូលដ្ឋានសំអាងគ្រប់គ្រាន់ និងអាចអនុវត្តបានទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ១៩៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ហើយសូមឱ្យការផ្តល់យោបល់នេះ រក្សានូវតុល្យភាពឱ្យបានយុត្តិធម៌ រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផង និងអ្នកធ្វើសេវាកម្មអគ្គិសនីផង**។

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ១៩៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ មានតម្កល់ទុកនៅ ........................................................................................ សម្រាប់សាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ មេត្តាជ្រាបជាពត៌មាន។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**